# សេចក្ដីប្រកាសដើម្បីទទួលយកជ័យជំនះ

រូបកាយរបស់ខ្ញុំគឺជាព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធ (១) ខ្ញុំត្រូវបានប្រោសលោះ (២) ខ្ញុំត្រូវបានសំអាត (៣)ខ្ញុំត្រូវបានញែកចេញជាបរិសុទ្ធដោយព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ (៤)។

អវយវៈរបស់ខ្ញុំគ្រប់ផ្នែកទាំងអស់ នៃរូបកាយរបស់ខ្ញុំ ទុកដូចជាប្រដាប់ប្រដាដ៏សុចរិត (៥) ប្រគល់ទៅដល់ព្រះសំរាប់ការបម្រើដល់ទ្រង់ ហើយសម្រាប់សិរីល្អរបស់ទ្រង់។

វិញ្ញាណអាក្រក់មិននៅក្នុងខ្លួនខ្ញុំ ហើយវាគ្មានអំណាចគ្រប់គ្រងលើខ្ញុំទេ នឹងមិនមានផលប៉ះពាល់ អំពីការចោទប្រកាន់ប្រឆាំងនឹងខ្ញុំ ទាំងអស់នេះត្រូវបានទូរទាត់ដោយព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ (៦)។

ខ្ញុំអាចយកឈ្នះលើអារក្សសាតាំងបានដោយសារតែឈាមរបស់កូនចៀម និងដោយសារទីបន្ទាល់របស់ខ្ញុំ ហើយក៏មិនបានស្ដាយជីវិតរបស់ខ្ញុំដរាបដល់ស្លាប់ (៧)។

រូបកាយរបស់ខ្ញុំគឺសម្រាប់ព្រះអម្ចាស់ ហើយព្រះអម្ចាស់គឺសម្រាប់រូបកាយរបស់ខ្ញុំ(៨)។

(១) ១កូរិនថូស ៦: ១៩
(២) អេភេសូរ ១: ៧
(២) ទំនុកតម្កើង ១០៧: ២
(៣) ១យ៉ូហាន ១: ៧
(៤) ហេព្រើរ ១៣: ១២
(៥) រ៉ូម ៦: ១៣
(៦) រ៉ូម ៨: ៣៣-៣៤
(៧) វិវរណៈ ១២: ១១
(៨) ១កូរិនថូស ៦: ១៣

**១កូរិនថូស ៦ : ១៩** តើមិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ ។

**អេភេសូរ ១: ៧** ហើយយើងបានសេចក្ដីប្រោសលោះនៅក្នុងព្រះរាជបុត្រានោះ ដោយសារព្រះលោហិតទ្រង់ គឺជាសេចក្ដីប្រោសឲ្យរួច ពីទោស តាមព្រះគុណដ៏ធ្ងន់ក្រៃលែងនៃទ្រង់ ។

**ទំនុកតម្កើង១០៧: ២** គួរឲ្យពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះបានថាដូច្នេះដែរ គឺអស់អ្នកដែលទ្រង់បានលោះឲ្យរួចពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវនោះ។

**១យ៉ូហាន ១: ៧** តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្ដីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់។

**ហេព្រើរ ១៣: ១២** ដូច្នេះ ព្រះយេស៊ូវទ្រង់ក៏បានរងទុក្ខ នៅខាងក្រៅទ្វារក្រុងដែរ ដើម្បីនឹងញែកប្រជាជនឲ្យបរិសុទ្ធ ដោយសារព្រះលោហិតនៃអង្គទ្រង់ ។

**រ៉ូម ៦ : ១៣** ក៏កុំឲ្យប្រគល់អវយវៈទាំងប៉ុន្មាន របស់អ្នករាល់គ្នាទៅក្នុងអំពើបាប ទុកដូចជាប្រដាប់ទុច្ចរិតនោះឡើយ គឺត្រូវប្រគល់ខ្លួនទៅព្រះ ដូចជាបានរស់ពីស្លាប់នោះឡើងវិញ ហើយថ្វាយអវយវៈរបស់អ្នករាល់គ្នាទៅព្រះ ទុកដូចជាប្រដាប់ប្រដាសុចរិតផង។

**រ៉ូម ៨ : ៣៣-៣៤** តើអ្នកណានឹងចោទប្ដឹងពីពួករើសតាំងរបស់ព្រះបាន ដ្បិតគឺជាព្រះហើយ ដែលទ្រង់រាប់គេជាសុចរិត ៣៤ តើអ្នកណានឹងកាត់ទោសគេបាន ដ្បិតព្រះគ្រីស្ទទ្រង់បានសុគតជំនួសគេហើយ តែដែលថា ទ្រង់រស់ឡើងវិញ នោះមានទំនងជាងទ្រង់ក៏គង់នៅខាងស្តាំនៃព្រះ ហើយជាអ្នកអង្វរជំនួសយើងរាល់គ្នាដែរ ។

**វិវរណៈ ១២ : ១១** គេបានឈ្នះវា ដោយសារឈាមនៃកូនចៀម ហើយដោយសារសេចក្ដីបន្ទាល់របស់គេ ក៏មិនបានស្ដាយជីវិតខ្លួនដរាបដល់ស្លាប់ ។

**១កូរិនថូស ៦ : ១៣** ឯចំណីអាហារ នោះសំរាប់ក្រពះ ហើយក្រពះក៏សំរាប់ចំណីអាហារដែរ តែព្រះទ្រង់នឹងឲ្យទាំង២យ៉ាងសាបសូន្យទៅ ឯរូបកាយ មិនមែនសំរាប់ការកំផិតទេ គឺសំរាប់តែព្រះអម្ចាស់វិញ ហើយព្រះអម្ចាស់ក៏សំរាប់រូបកាយដែរ។

**បកប្រែដោយ: ONE -2- ONE CAMBODIA**

**អាស័យដ្ឋានៈ # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**

**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**

www.One-2-One world.org

www.derekprince.co.nz PC04